# ខ និងលក្ខខណ្ឌនៃការប្រើប្រាស់កម្មវិធី STARBUCKS REWARDS

ត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២៤

សូមអានលក្ខខណ្ឌនៃការប្រើប្រាស់នេះឱ្យបានប្រុងប្រយ័ត្ន ។ តាមរយៈការចូលរួម ឬការប្រើប្រាស់កម្មវិធី Starbucks Rewards លោកអ្នកយល់ព្រមអនុវត្តតាមលក្ខខណ្ឌនៃការប្រើប្រាស់នេះ និងលក្ខខណ្ឌផ្សេងទៀត ដែលមានភ្ជាប់ជាអំណះអំណាង ។ ប្រសិនបើលោកអ្នកមិនយល់ព្រមអនុវត្តតាមលក្ខខណ្ឌនៃការប្រើប្រាស់នេះទេ សូមមេត្តាកុំចូលរួម ឬ ប្រើប្រាស់កម្មវិធី Starbucks Rewards នេះ ។

១. លក្ខខណ្ឌទូទៅ

១.១ លក្ខខណ្ឌនៃការប្រើប្រាស់នេះ អនុវត្តលើរាល់ការចូលរួម ការប្រើប្រាស់ទៅលើផ្នែកណាមួយ ឬទាំងស្រុង នៃគេហទំព័រ ឬកម្មវិធីទូរស័ព្ទ និងការចូលរួមក្នុងកម្មវិធី Starbucks Rewards ដែលដាក់ឱ្យប្រតិបត្តិការដោយក្រុមហ៊ុន Coffee Concepts (Cambodia) Limited (តទៅនេះហៅថា "**Starbucks**", "យើងខ្ញុំ" "របស់យើងខ្ញុំ") ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពី Starbucks Coffee International, Inc ក្នុងព្រះរាជាណាចក្រកម្ពុជា ។ លក្ខខណ្ឌនៃការប្រើប្រាស់នេះ មិនកែប្រែ ខ និងលក្ខខណ្ឌ ឬកិច្ចព្រមព្រៀងណាមួយដទៃទៀត ដែលលោកអ្នកអាចមានជាមួយ Starbucks ដែលទាក់ទងនឹងផលិតផល និង សេវាកម្មដទៃទៀត ទោះបីជាក្នុងទម្រង់ណាក៏ដោយ ។

១.២ លោកអ្នកយល់ព្រមថា យើងខ្ញុំអាចផ្តល់ព័ត៌មានថ្មីៗ ការជូនដំណឹង ការបង្ហាញ និងការកែប្រែចំពោះលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ និងព័ត៌មានផ្សេងទៀតទាក់ទងនឹងកម្មវិធី Starbucks Rewards ដោយមធ្យោបាយអេឡិចត្រូនិច រួមទាំងការបង្ហោះព័ត៌មាន និងសម្ភារៈទាំងនោះតាមអ៊ីនធឺណិតនៅគេហទំព័រ https://www.starbucks.com.kh ("គេហទំព័រ Starbucks") ។

២. ការកែប្រែ ខនិងលក្ខខណ្ឌ

Starbucks រក្សាសិទ្ធិក្នុងការកែប្រែ ផ្លាស់ប្តូរ ទាំងស្រុង ឬដោយឡែក និង/ឬបញ្ចប់កម្មវិធី Starbucks Rewards និង/ឬ លក្ខខណ្ឌនៃការប្រើប្រាស់ ឬគោលការណ៍ដទៃទៀតណាមួយ ការផ្តល់ព័ត៌មាន ឬការណែនាំទាក់ទងទៅនឹងកម្មវិធី Starbucks Rewards ក្នុងពេលណាមួយ តាមឆន្ទានុសិទ្ធិរបស់ខ្លួនតែមួយគត់ ។ រាល់ការកែប្រែ ឬផ្លាស់ប្តូរត្រូវមានអានុភាពភ្លាមៗ និងអាចត្រូវបានបោះផ្សាយនៅលើគេហទំព័រ Starbucks ហើយលោកអ្នកបោះបង់រាល់សិទ្ធិទាំងអស់ ដែលលោកអ្នកអាចមានសម្រាប់ការទទួលបានការជូនដំណឹងអំពីការកែប្រែ ឬការផ្លាស់ប្តូរខាងលើនេះ ។ ការបន្តចូលរួមរបស់លោកអ្នកក្នុងកម្មវិធី Starbucks Rewards បន្ទាប់ពីការកែប្រែ ឬ ការផ្លាស់ប្តូរខនិងលក្ខខណ្ឌនេះ បញ្ជាក់អំពីការយល់ព្រមរបស់លោកអ្នក

ទៅលើលក្ខខណ្ឌនៃការប្រើប្រាស់នេះ រួមទាំងការកែប្រែ ឬការផ្លាស់ប្តូរផ្សេងៗទៀត ហេតុដូច្នេះលោកអ្នកគួរតែត្រួតពិនិត្យលក្ខខណ្ឌនៃការប្រើប្រាស់ គោលការណ៍អនុវត្ត និងព័ត៌មានពាក់ព័ន្ធឱ្យបានទៀងទាត់ ដើម្បីស្វែងយល់ពីខ និងលក្ខខណ្ឌដែលអនុវត្តលើការប្រើប្រាស់កម្មវិធី Starbucks Rewards នេះ ។ ប្រសិនបើលោកអ្នកមិនយល់ព្រមតាមលក្ខខណ្ឌនៃការប្រើប្រាស់នេះទេ លោកអ្នកត្រូវតែបញ្ឈប់ការចូលរួម និងការប្រើប្រាស់កម្មវិធី Starbucks Rewards ។

៣. ការប្រើប្រាស់ផ្ទាល់ខ្លួន

៣.១ កម្មវិធី Starbucks Rewards បង្កើតឡើងក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ការប្រើប្រាស់ជា លក្ខណៈពាណិជ្ជកម្មត្រូវបានហាមឃាត់ ។ កម្មវិធីនេះមិនបានបង្កើតឡើង ដោយសំដៅដល់ ឬក្នុងគោលបំណងសម្រាប់ឲ្យជនដែលមានអាយុក្រោមដប់ប្រាំបី (១៨) ឆ្នាំប្រើប្រាស់នោះឡើយ ។ ប្រសិនបើលោកអ្នកមានអាយុចន្លោះពី១៣ឆ្នាំ ទៅក្រោម១៨ឆ្នាំ លោកអ្នកគួរតែត្រួតពិនិត្យខនិងលក្ខខណ្ឌនៃការប្រើប្រាស់កម្មវិធី Starbucks Rewards នេះជាមួយឪពុកម្តាយ ឬអាណាព្យាបាលរបស់លោកអ្នក ដើម្បីឲ្យប្រាកដថាលោកអ្នក និងឪពុកម្តាយ ឬ អាណាព្យាបាល យល់និងឯកភាពទៅនឹងខនិងលក្ខខណ្ឌនេះ ។ ប្រសិនបើឪពុកម្តាយ ឬអាណាព្យាបាលរបស់លោកអ្នក មិនយល់ស្របនឹងខនិងលក្ខខណ្ឌនេះទេ លោកអ្នកត្រូវតែបញ្ឈប់ការប្រើប្រាស់កម្មវិធី Starbucks Rewards ។

៣.២ <u>គោលការណ៍សិទ្ធិឯកជន</u> របស់យើង ត្រូវបានរួមបញ្ចូលទៅក្នុង ខនិងលក្ខខណ្ឌនេះ ហើយវាគ្រប់គ្រងទៅលើការចូលរួមប្រើប្រាស់របស់លោកអ្នកក្នុងកម្មវិធី Starbucks Rewards ។ សូមលោកអ្នកអាន <u>គោលការណ៍សិទ្ធិឯកជន</u> ឱ្យបានប្រុងប្រយ័ត្ន ដើម្បីស្វែងយល់អំពីវិធីដែល Starbucks ប្រមូល ប្រើប្រាស់ និងផ្សព្វផ្សាយព័ត៌មានរបស់អតិថិជន និងវិធីសាស្ត្រក្នុងការធ្វើបច្ចុប្បន្នភាព ឬការផ្លាស់ប្តូរព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ក៏ដូចជាវិធីដែលយើងធ្វើការទំនាក់ទំនងជាមួយលោកអ្នក ។ តាមរយៈការចូលរួមក្នុងកម្មវិធី Starbucks Rewards លោកអ្នកយល់ព្រម យល់ស្រប និងព្រមព្រៀង លើរាល់សកម្មភាពទាំងអស់របស់យើងខ្ញុំ ដែលទាក់ទងនឹងទិន្នន័យព័ត៌មានរបស់លោកអ្នក ស្របទៅតាមគោលការណ៍សិទ្ធិឯកជនរបស់យើងខ្ញុំ ។

៣.៣ Starbucks មិនត្រូវទទួលខុសត្រូវលើរាល់ព័ត៌មានណាមួយរបស់លោកអ្នក ដែលបានរក្សាទុក ឬផ្សព្វផ្សាយដោយលោកអ្នក ឬតតិយជន ឬការខាតបង់ ឬខូចខាតដែលបណ្តាលមកពីការរក្សាទុក ឬការផ្សព្វផ្សាយព័ត៌មាននោះទេ ហើយ Starbucks ក៏មិនត្រូវទទួលខុសត្រូវផងដែរ លើរាល់ទង្វើ ឬការប្រព្រឹត្តិកំហុសណាមួយរបស់អ្នកប្រើប្រាស់ឡើយ ។ លោកអ្នកគឺជាអ្នកទទួលខុសត្រូវទាំងស្រុងលើរាល់ការចូលរួមក្នុងកម្មវិធី Starbucks Rewards ។

៣.៤ ក្នុងករណីដែលលោកអ្នកប្រើប្រាស់កុំព្យូទ័រសាធារណៈ ឬមានបុគ្គលច្រើននាក់បានប្រើប្រាស់កុំព្យូទ័រតែមួយ ដើម្បីចូលក្នុងគណនី Starbucks Rewards របស់លោកអ្នក លោកអ្នកត្រូវតែប្រាកដថាខ្លួនបានអនុវត្តតាមរាល់ការណែនាំដែលពាក់ព័ន្ធ ដើម្បីធានាថាលោកអ្នកបានផ្តាច់ការតភ្ជាប់ និងបានចាកចេញពីគណនី ក្នុងប្រព័ន្ធកុំព្យូទ័រដែលលោកអ្នកកំពុងប្រើប្រាស់នោះបានយ៉ាងត្រឹមត្រូវ ដើម្បីការពារកុំឲ្យមានការប្រើប្រាស់គណនីនោះដោយគ្មានការអនុញ្ញាត ក៏ដូចជាការប្រើប្រាស់កាត Starbucks របស់អ្នកលោក ។

៤. អំពីកម្មវិធី Starbucks Rewards

កម្មវិធី Starbucks Rewards គឺជាវិធីមួយដែល Starbucks ប្រើប្រាស់សម្រាប់ជាការផ្តល់រង្វាន់ និងអរគុណដល់អតិថិជនដែលមានភាពស្មោះត្រង់របស់ខ្លួន ក្នុងការគាំទ្រអាជីវកម្ម និងជាវផលិតផល Starbucks ។ សមាជិករបស់កម្មវិធី Starbucks Rewards មានឱកាសទទួលបាន និងសន្សំ "**ផ្កាយ**" ដែលអាចប្តូរមកជាការទទួលបានអត្ថប្រយោជន៍ផ្សេងៗ ពីក្នុងកម្មវិធី Starbucks Rewards ដែលត្រូវបានគេស្គាល់ផងដែរថាជា "**រង្វាន់**" នៅតាមបណ្តាហាង Starbucks នានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥. កាត Starbucks

កាត Starbucks សំដៅដល់កាតប្លាស្ទិកដែលមានបិតម៉ាក Starbucks ដែលអតិថិជនអាចប្រើប្រាស់ច្រើនដង ហើយអាចបញ្ចូល ឬបន្ថែមលុយក្នុងកាតនោះសម្រាប់ប្រើប្រាស់ដើម្បីធ្វើការជាវក្នុងហាង Starbucks ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។ កាត Starbucks អាចប្រើប្រាស់បានតែនៅក្នុងហាង Starbucks ណាមួយនៃ ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ហើយត្រូវតែដាក់ឱ្យចាប់ផ្តើមដំណើរការតាមរយៈការបញ្ចូលទឹកប្រាក់យ៉ាងតិច ចំនួន ប្រាំ (៥) ដុល្លារអាមេរិកសម្រាប់ការប្រើប្រាស់លើកដំបូង ។ ប្រសិនបើលោកអ្នកចង់ជាវកាត Starbucks ជាកាតកាដូ នោះ កាតទាំងនោះគ្រាន់តែត្រូវដាក់ឱ្យចាប់ផ្តើមដំណើរការតែប៉ុណ្ណោះ ។ នៅពេលដែលលោកអ្នកបានដាក់កាត Starbucks នោះឱ្យចាប់ផ្តើមដំណើរការរួចហើយ លោកអ្នកនឹងអាចប្រើប្រាស់កាតនោះដើម្បីធ្វើការជាវបាន ។ ក៏ប៉ុន្តែកាត Starbucks មិនអាចយកមកទូទាត់សង ឬដូរជាសាច់ប្រាក់ ឬសមតុល្យឥណទានបានឡើយ ។ ជាទូទៅ លោកអ្នកអាចពិនិត្យមើលសមតុល្យរបស់លោកអ្នកបាន តាមរយៈការសាកសួរទៅកាន់បុគ្គលិកក្នុងហាង Starbucks ណាមួយនៃព្រះរាជាណាចក្រកម្ពុជា ឬតាមរយៈគេហទំព័រ http://www.starbucks.com.kh/card ឬតាមរយៈកម្មវិធីទូរស័ព្ទ Starbucks Cambodia ប្រសិនបើលោកអ្នកបាន ចុះឈ្មោះចូលរួមកម្មវិធី Starbucks Rewards ។ នៅពេលដែលសមតុល្យក្នុងកាត Starbucks របស់លោកអ្នកមានចំនួនតិច នោះលោកអ្នកអាចបញ្ចូលទឹកប្រាក់ទៅក្នុងកាត Starbucks បន្ថែមទៀតបាន ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លោកអ្នកអាចបញ្ចូលទឹកប្រាក់ទៅក្នុងកាត Starbucks របស់លោកអ្នក ជារូបិយបណ្ណដុល្លារអាមេរិក ក្នុងចំនួនចន្លោះពី ពីរដុល្លារអាមេរិក និងហាសិបសេន (USD2.50) រហូតដល់ប្រាំរយដុល្លារអាមេរិក (USD500.00) ដោយទឹកប្រាក់ចំនួនប្រាំរយដុល្លារ អាមេរិកនេះ (USD500.00) ជាចំនួនទឹកប្រាក់អតិបរមា ដែលអាចរក្សាទុកក្នុងកាតនាពេលណាក៏បាន

។ លោកអ្នកត្រូវតែដាក់កាត Starbucks ឱ្យចាប់ផ្តើមដំណើរការ ឬបញ្ចូលទឹកប្រាក់ក្នុងកាត Starbucks តាមរយៈការបង់ជាសាច់ប្រាក់ ឬប្រើប្រាស់កាតឥណទាន តែលោកអ្នកមិនអាចប្រើកាត Starbucks មួយដើម្បីបញ្ចូលទឹកប្រាក់ទៅឲ្យកាត Starbucks មួយផ្សេងទៀតបានទេ ។

កាត Starbucks របស់លោកអ្នកនឹងផុតកំណត់ក្នុងរយៈពេលបី (៣) ឆ្នាំ បន្ទាប់ពីការធ្វើប្រតិបត្តិការហិរញ្ញវត្ថុចុងក្រោយគេបង្អស់ ។ ពាក្យ "ប្រតិបត្តិការហិរញ្ញវត្ថុ" សំដៅដល់សកម្មភាពណាមួយដូចខាងក្រោម៖

- ការចាប់ផ្តើមដំណើរការកាត
- ការបញ្ចូលទឹកប្រាក់
- ការប្តូរយករង្វាន់សម្រាប់កាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួច
- ប្រតិបត្តិការជាវ និង
- ការផ្ទេរប្រាក់ (តាមនិយមន័យដូចខាងក្រោម) រវាងកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួច ។

នៅពេលកាត Starbucks មានការផុតកំណត់ ឬមានការផ្លាស់ប្តូរណាមួយលើបទបញ្ញត្តិច្បាប់ ការអនុវត្ត នីតិវិធី និងរចនាសម្ព័ន្ធដែលធ្វើឲ្យកាត Starbucks លែងមានសុពលភាព ឬប្រសិទ្ធិភាព នោះសមតុល្យដែលនៅសល់ក្នុងកាត Starbucks នោះនឹងត្រូវទុកជាមោឃៈភ្លាមៗ ដោយពុំចាំបាច់មានការជូនដំណឹងដល់លោកអ្នកឡើយ ។ សមតុល្យដែលនៅសល់ក្នុងកាត Starbucks នោះនឹងក្លាយជាចំណូលរបស់ Starbucks ហើយ Starbucks មិនត្រូវមានការទទួលខុសត្រូវ ឬកាតព្វកិច្ចអ្វីទាំងអស់ចំពោះម្ចាស់កាត Starbucks នោះ ។ ដើម្បីជៀសវាងការមន្ទិលសង្ស័យ (ដោយមិនគិតដល់អ្វីដែលបានកំណត់ផ្ទុយពីលក្ខខណ្ឌនៃការប្រើប្រាស់នេះ) សមតុល្យដែលនៅសល់មិនអាចធ្វើការទូទាត់សងវិញបានឡើយ ។

៦. ការចូលជាសមាជិកក្នុងកម្មវិធី Starbucks Rewards

លោកអ្នកអាចចុះឈ្មោះក្នុងកម្មវិធី Starbucks Rewards ហើយចាប់ផ្តើមសន្សំផ្កាយតាមរយៈការចូលទៅកាន់គេហទំព័រ Starbucks ឬការបញ្ចូលកម្មវិធីទូរស័ព្ទ Starbucks Cambodia ហើយអនុវត្តតាមការណែនាំដើម្បីបង្កើតគណនី Starbucks Rewards ហើយចុះបញ្ជីកាត Starbucks (យ៉ាងតិចចំនួនមួយ (១)) ទៅក្នុងគណនី Starbucks Rewards នោះ ។ បន្ទាប់ពីការចុះឈ្មោះបង្កើតគណនីរួច លោកអ្នកនឹងទទួលបាន អ៊ីម៉ែលបញ្ជាក់ពីការចុះឈ្មោះនោះ ផ្ញើទៅកាន់អាសយដ្ឋានអ៊ីម៉ែលរបស់លោកអ្នក ដែលបានប្រើប្រាស់សម្រាប់ការចុះឈ្មោះ និងដាក់ឱ្យចាប់ផ្តើមដំណើរការគណនីរបស់លោកអ្នក ។ ប្រសិនបើលោកអ្នកមិនបានទទួលអ៊ីម៉ែលបញ្ជាក់ពីការចុះឈ្មោះនោះក្នុងរយៈពេល ២៤ម៉ោង សូមធ្វើការទំនាក់ទំនងមកមជ្ឈមណ្ឌលសេវាកម្ម អតិថិជនរបស់ Starbucks Rewards តាមរយៈលេខទូរស័ព្ទទំនាក់ទំនង៖ (៨៥៥) ២៣ ៩៨៦ ៥៩១ ។

ដំណើរការនៃការចុះឈ្មោះតម្រូវឱ្យលោកអ្នកផ្តល់ព័ត៌មានដូចតទៅ៖ លេខកូតសម្ងាត់ អ៊ីម៉ែល (ទាមទារដើម្បីទទួលបាន Rewards ទាំងអស់) អាសយដ្ឋាន លេខទូរស័ព្ទ លេខកូតកាត Starbucks និងលេខសម្ងាត់

លើកាត ថ្ងៃខែឆ្នាំកំណើត ឈ្មោះ និងជម្រើសរបស់អ្នកពាក់ព័ន្ធនឹងការទទួលបានព័ត៌មាន និងកម្មវិធីពិសេសផ្សេងៗអំពីកម្មវិធី ។

លោកអ្នកអាចចុះបញ្ជីកាត Starbucks ចូលទៅក្នុងគណនីរបស់លោកអ្នកនៅពេលណាក៏បាន ក៏ប៉ុន្តែលោកអ្នកអាចមានគណនីសម្រាប់ខ្លួនឯងតែមួយ (១) គត់ ។ លោកអ្នកអាចចុះបញ្ជី ឬបន្ថែមកាត Starbucks ក្នុងចំនួនច្រើនបំផុតត្រឹមម្ភៃ (២០) កាតទៅក្នុងគណនីរបស់លោកអ្នក ។ លោកអ្នកអាចធ្វើការផ្ទេរសមតុល្យទាំងស្រុងពីកាត Starbucks មួយ ("**កាតដែលត្រូវបានផ្ទេរ**") ទៅកាត Starbucks មួយទៀតបាន ("**ការផ្ទេរប្រាក់**") តាមរយៈគណនីតែមួយ ប៉ុន្តែការផ្ទេរសមតុល្យដោយផ្នែកមិនត្រូវបានអនុញ្ញាតទេ ។ កាតដែលត្រូវបានផ្ទេរនោះ នឹងប្រែក្លាយទៅជាកាតទទេ ប៉ុន្តែនៅតែបន្តមានសុពលភាពសម្រាប់ការប្រើប្រាស់ និងបញ្ចូលប្រាក់បន្តទៀតបាន ។ ការផ្ទេរសមតុល្យក្នុងកាត Starbucks អាចធ្វើបានដោយខ្លួនរបស់លោកអ្នកផ្ទាល់តាមរយៈការចូលទៅកាន់គេហទំព័រ ឬកម្មវិធីទូរស័ព្ទ Starbucks Cambodia ។

៧. ចំនួនផ្កាយដែលសន្សំបាន

មានតែប្រតិបត្តិការដែលបានទូទាត់តាមរយៈកាត Starbucks តែប៉ុណ្ណោះ ដែលអាចទទួលបានផ្កាយសម្រាប់បញ្ចូលទៅក្នុងគណនី Starbucks Rewards បាន ។

អត្ថប្រយោជន៍ដែលលោកអ្នកអាចទទួលបានពីកម្មវិធី Starbucks Rewards គឺអាស្រ័យទៅលើចំនួនផ្កាយដែលលោកអ្នកសន្សំបាន ។ លោកអ្នកអាចសន្សំចំនួនផ្កាយនេះ តាមរយៈការជាវពីក្នុងហាង Starbucks ណាមួយនៅក្នុងប្រទេសកម្ពុជា ដោយលោកអ្នកត្រូវបង្ហាញកាត Starbucks របស់លោកអ្នក ដែលបានចុះបញ្ជីនៅក្នុងប្រព័ន្ធរួចហើយ ឬបារកូដនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia ទៅកាន់បុគ្គលិករបស់ Starbucks នៅពេលទូទាត់ប្រាក់ ឬតាមរយៈមុខងារការកុម្ម៉ង់និងទូទាត់នៅលើកម្មវិធីទូរសព្ទ Starbucks Cambodia (Mobile Order and Pay Functions)។

សូមបញ្ជាក់ថាការចំណាយនឹងត្រូវយកមកគណនា ហើយចំនួនផ្កាយនឹងត្រូវបានរាប់បញ្ចូល តែក្នុងករណីដែលកាត Starbucks របស់លោកអ្នក ត្រូវបានចុះបញ្ជីនៅក្នុងប្រព័ន្ធ សម្រាប់គណនី Starbucks Rewards របស់លោកអ្នករួចហើយ ។ បន្ថែមពីនេះ លោកអ្នកត្រូវបង្ហាញកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរបស់លោកអ្នករួចហើយ ឬបារកូដនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia សម្រាប់ស្កេន (Scan) នៅពេលទូទាត់ប្រាក់ ។

ចំនួនផ្កាយនឹងមិនត្រូវបានផ្តល់ឱ្យចំពោះការជាវទាំងឡាយណា ដែលប្រើកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធ នៅក្នុងហាង Starbucks ណាមួយក្រៅពីប្រទេសកម្ពុជា ឬសម្រាប់ការជាវកាត Starbucks gift ឡើយ ។

លោកអ្នកនឹងទទួលបានចំនួនផ្កាយ អាស្រ័យទៅតាមតម្លៃនៃការជាវរបស់លោកអ្នក ដោយលោកអ្នកនឹងទទួលបានផ្កាយចំនួន ១ (មួយ) សម្រាប់ការចំណាយអស់ទឹកប្រាក់ចំនួន ៥០ សេន ដុល្លារអាមេរិក តាមរយៈកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួច ។ តាមរយៈឆន្ទានុសិទ្ធិរបស់ Starbucks ចំនួនផ្កាយអាចត្រូវបានផ្តល់ឲ្យក្នុងចំនួនណាមួយ អាស្រ័យទៅតាមតម្លៃនៃការជាវ ដែលបានទូទាត់ពេញលេញ តាមរយៈកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរួចប៉ុណ្ណោះ ។

ជាទូទៅចំនួនផ្កាយដែលបានពីការជាវពីក្នុងហាង Starbucks នឹងត្រូវបញ្ចូលទៅក្នុងគណនីរបស់លោកអ្នកភ្លាមៗដោយស្វ័យប្រវត្តិ បន្ទាប់ពីប្រតិបត្តិការត្រូវបានបញ្ចប់ ឬក្នុងរយៈពេលប្រមាណ សែសិបប្រាំបី (៤៨) ម៉ោង ។ ជារឿយៗ យើងខ្ញុំ ឬអ្នកដែលទទួលបានការអនុញ្ញាតពីយើងខ្ញុំ អាចផ្តល់ជូនអ្នកនូវកម្មវិធីពិសេស ដោយផ្តល់នូវផ្កាយសម្រាប់កម្មវិធីពិសេសនោះ (Promotional Stars) ។ ផ្កាយសម្រាប់កម្មវិធីពិសេស (Promotional Stars) ដូចជាចំនួនផ្កាយបន្ថែមជាដើម អាចត្រូវបានផ្តល់ឲ្យស្របតាមការផ្តល់កម្មវិធីពិសេស ដែលពាក់ព័ន្ធ បូករួមជាមួយនិង លក្ខខណ្ឌបន្ថែមផ្សេងទៀត ដែលបានកំណត់សម្រាប់ការផ្តល់កម្មវិធីពិសេសនោះ ។

## ៨. កម្រិតអត្ថប្រយោជន៍នៃកម្មវិធី Starbucks Rewards

បច្ចុប្បន្នអត្ថប្រយោជន៍នៃកម្មវិធី Starbucks Rewards មានចំនួន ពីរ (២) កម្រិត ដែលត្រូវបានកំណត់តាមរយៈចំនួនផ្កាយ ដែលបានសន្សំនៅក្នុងគណនីរបស់លោកអ្នក សម្រាប់រាល់រយៈពេល ១២ (ដប់ពីរ) ខែជាប់ៗគ្នា ។ តាមរយៈការបើកគណនី និងការចុះបញ្ជីកាត Starbucks ដែលបានដំណើរការរួចនៅក្នុងប្រព័ន្ធ លោកអ្នកនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិទៅក្នុងកម្មវិធី Starbucks Rewards ដោយទទួលបានអត្ថប្រយោជន៍ត្រឹមកម្រិតសមាជិកបៃតង (Green Level) ។ ប្រសិនបើលោកអ្នកសន្សំបានផ្កាយថ្មីចំនួន ពីររយ (២០០) ផ្កាយ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះឈ្មោះ លោកអ្នកនឹងទទួលបានអត្ថប្រយោជន៍ត្រឹមកម្រិតសមាជិកមាស (Gold Level) ។

នៅពេលលោកអ្នកទទួលបានកម្រិតណាមួយនៃអត្ថប្រយោជន៍ ដែលមានក្នុងកម្មវិធី Starbucks Rewards លោកអ្នកនឹងទទួលបានអត្ថប្រយោជន៍ជាក់លាក់សម្រាប់កម្រិតអត្ថប្រយោជន៍នោះ ។

ដើម្បីរក្សាអត្ថប្រយោជន៍ទាំងអស់ ដែលបានផ្តល់ឱ្យសម្រាប់កម្រិតអត្ថប្រយោជន៍សមាជិកបៃតង លោកអ្នកគ្រាន់តែចុះបញ្ជីលើកាត Starbucks ដែលបានដំណើរការរួចណាមួយ ទៅក្នុងគណនីរបស់លោកអ្នក ។

ដើម្បីរក្សាអត្ថប្រយោជន៍ទាំងអស់ ដែលបានផ្តល់ឱ្យសម្រាប់កម្រិតអត្ថប្រយោជន៍សមាជិកមាស លោកអ្នកត្រូវសន្សំផ្កាយថ្មីឲ្យបានយ៉ាងតិច ចំនួន ២០០ (ពីររយ) ផ្កាយ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ជាប់ៗគ្នា បន្ទាប់ពីកាលបរិច្ឆេទដែលលោកអ្នកឈានដល់កម្រិតអត្ថប្រយោជន៍សមាជិកមាស ។ នាកាលបរិច្ឆេទគម្រប់ខួបនៃការទទួលបានកម្រិតអត្ថប្រយោជន៍សមាជិកមាស ការរាប់ចំនួនផ្កាយនឹងត្រូវចាប់ផ្តើមសារជាថ្មី ។ ការគិតឡើងវិញនៃកម្រិតអត្ថប្រយោជន៍សមាជិកមាសនេះ មានន័យថា ចំនួនផ្កាយនឹងត្រូវប្តូរជាស្វ័យប្រវត្តិ ទៅជាចំនួនភេសជ្ជៈដែលផ្តល់ឲ្យដោយមិនគិតថ្លៃ (គិតបង្គ្រប់ចុះ) ហើយចំនួនផ្កាយដែលនៅសល់នឹងត្រូវបានបង្ហាញបន្ទាប់ពីការប្តូរនេះ ។ ឧទាហរណ៍ ប្រសិនបើលោកអ្នកមានផ្កាយចំនួន ១៥០ (មួយរយហាសិប)

ផ្កាយ ការគិតឡើងវិញនៃកម្រិតអត្ថប្រយោជន៍សមាជិកមាស មានន័យថាអ្នកមានសិទ្ធិទទួលបានភេសជ្ជៈ ចំនួន ១ (មួយ) កែវ ដែលផ្តល់ឲ្យដោយមិនគិតថ្លៃ ហើយអ្នកនឹងត្រូវមានផ្កាយចំនួន ៥០ (ហាសិប) ផ្កាយទៀត ដែលនៅសល់ ។

សូមបញ្ជាក់ផងដែរថា ចំនួនផ្កាយដែលសន្សំបាននៅកម្រិតអត្ថប្រយោជន៍នីមួយៗ នៅក្នុងកម្មវិធី Starbucks Rewards មានសុពលភាពសម្រាប់តែរយៈពេល ១២ (ដប់ពីរ) ខែ ដោយគិតចាប់ពីកាលបរិច្ឆេទដែលលោកអ្នកឈានដល់កម្រិតអត្ថប្រយោជន៍ណាមួយ ។ យ៉ាងណាមិញ រាល់រង្វាន់ដែលលោកអ្នកសន្សំបាន ប៉ុន្តែមិនបានប្តូរ ហើយមិនទាន់ផុតកំណត់ នឹងបន្តរក្សាទុកនៅក្នុងគណនីរបស់លោកអ្នក ហើយលោកអ្នកអាចប្តូរយករង្វាន់នោះបាន ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងនេះ ។

លោកអ្នកអាចពិនិត្យ ឬតាមដានចំនួនផ្កាយរបស់លោកអ្នកដែលនៅសល់ និងរង្វាន់ដែលមានផ្តល់ឲ្យតាមរយៈ គេហទំព័រ Starbucks ឬកម្មវិធីទូរស័ព្ទ Starbucks Cambodia ។ Starbucks រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរ កម្រិតអត្ថប្រយោជន៍មួយចំនួន និងផ្លាស់ប្តូរអត្ថប្រយោជន៍ និងរង្វាន់ដែលមានសម្រាប់កម្រិតអត្ថប្រយោជន៍នីមួយៗ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

## ៨.១ កម្រិតអត្ថប្រយោជន៍សមាជិកបៃតង (Green Level)

ដោយគ្រាន់តែចុះបញ្ជីកាត Starbucks ដែលបានដំណើរការរួចទៅក្នុងប្រព័ន្ធ លោកអ្នកនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិនៅក្នុងកម្រិតអត្ថប្រយោជន៍សមាជិកបៃតង (Green Level) នៃកម្មវិធី Starbucks Rewards ។ ប្រសិនបើ លោកអ្នកមិនអាចសន្សំបានផ្កាយចំនួន ២០០ (ពីររយ) ផ្កាយ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ដើម្បីតម្លើងទៅដល់កម្រិតអត្ថប្រយោជន៍សមាជិកមាសទេ លោកអ្នកនឹងបន្តស្ថិតនៅក្នុងកម្រិតអត្ថប្រយោជន៍សមាជិកបៃតង ហើយផ្កាយរបស់លោកអ្នកនឹងត្រូវគិតឡើងវិញពីសូន្យ (0) ។ រង្វាន់ដែលមានសម្រាប់កម្រិតអត្ថប្រយោជន៍សមាជិកបៃតងរួមមាន៖

- រង្វាន់សម្រាប់ថ្ងៃកំណើត ។ លោកអ្នកនឹងទទួលបានភេសជ្ជៈទំហំ Tall មួយកែវ នៅក្នុងខែនៃថ្ងៃកំណើតរបស់លោកអ្នក ដូចដែលបានកំណត់ខាងក្រោម៖
  រង្វាន់សម្រាប់ថ្ងៃកំណើត នឹងត្រូវរាប់បញ្ចូលដោយស្វ័យប្រវត្តិនៅក្នុងគណនីរបស់លោកអ្នក នៅថ្ងៃទី១ នៃខែនៃថ្ងៃកំណើតរបស់លោកអ្នក ។ ការផ្តល់រង្វាន់សម្រាប់ថ្ងៃកំណើតនេះ នឹងត្រូវផុតកំណត់នៅថ្ងៃបន្ទាប់ពីខែនៃថ្ងៃកំណើតរបស់លោកអ្នក ។ លោកអ្នកត្រូវបង្ហាញកាត Starbucks ដែលបានបានចុះបញ្ជីក្នុងប្រព័ន្ធរួច ឬបារកូដនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia ទៅកាន់បុគ្គលិក Starbucks នៅក្នុងហាង Starbucks ដើម្បីប្តូរយករង្វាន់របស់លោកអ្នក ។ លោកអ្នកទទួលបានរង្វាន់សម្រាប់ថ្ងៃកំណើតតែមួយប៉ុណ្ណោះ ដោយមិនគិតពីចំនួនកាត Starbucks ដែលបានចុះបញ្ជី ដែលអ្នកមានឡើយ ។ រង្វាន់សម្រាប់ថ្ងៃកំណើតអាចប្តូរបានតែនៅក្នុងហាង Starbucks នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ហើយមិនត្រូវបានអនុវត្តចំពោះ ភេសជ្ជៈដែលរៀបចំស្រេចនៅក្នុងដបនោះទេ (ready-to-drink bottled beverages) ។
- ចំនួនផ្កាយទ្វេដង សម្រាប់ការជាវលើកដំបូង ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃបន្ទាប់ពីចុះបញ្ជីក្នុងប្រព័ន្ធរួច ។

- ទទួលបានផ្កាយចំនួន ៥ (ប្រាំ) បន្ថែម សម្រាប់រាល់ការជាវភេសជ្ជៈ ផ្តល់ជូនមានកំណត់នីមួយៗ (promotional beverage) ក្នុងសប្តាហ៍ដំបូងនៃការចេញលក់ ។

## ៨.២ កម្រិតអត្ថប្រយោជន៍សមាជិកមាស

បន្ទាប់ពីទទួលបានផ្កាយចំនួនពីររយ (២០០) ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ លោកអ្នកនឹងត្រូវបានបញ្ចូលមក "**កម្រិតអត្ថប្រយោជន៍សមាជិកមាស (Gold Level)**" ហើយសមតុល្យនៃចំនួនផ្កាយនឹងត្រូវកំណត់សារជាថ្មី ។ សម្រាប់ជាព័ត៌មាន ការកំណត់សារជាថ្មីសម្រាប់កំរិតអត្ថប្រយោជន៍សមាជិកមាសមានន័យថា ចំនួនផ្កាយទាំងអស់នឹងត្រូវប្តូរជាចំនួនភេសជ្ជៈដោយឥតគិតថ្លៃ (គិតបង្គ្រប់ចុះ) ហើយបន្ទាប់មកវានឹងបង្ហាញតែចំនួនផ្កាយដែលនៅសល់បន្ទាប់ពីការកំណត់សារជាថ្មីនេះតែប៉ុណ្ណោះ ។ អត្ថប្រយោជន៍ដែលបានមកពីកម្រិតអត្ថប្រយោជន៍សមាជិកមាស មានដូចខាងក្រោម ប្រសិនបើក្នុងរយៈពេល ដប់ពីរ (១២) ខែ នៅពេលដែលលោកអ្នកបានឈានដល់ ឬនៅរក្សាកំរិតសមាជិកមាសដដែល៖

- រង្វាន់ចំពោះកម្រិតអត្ថប្រយោជន៍សមាជិកបៃតង៖ លោកអ្នកនៅតែអាចប្តូរយករង្វាន់ ទាំងឡាយណាដែលមិនទាន់បានប្តូរ ពីកម្រិតអត្ថប្រយោជន៍សមាជិកបៃតង ដែលមិនទាន់ផុតកំណត់មុនពេលដែលលោកអ្នកបានដល់កម្រិតអត្ថប្រយោជន៍សមាជិកមាស ។ ប៉ុន្តែលោកអ្នកត្រូវតែប្តូររង្វាន់ដែលមិនទាន់ប្រើប្រាស់ទាំងនោះ ក្នុងរយៈពេលសុពលភាពរបស់វា ។
- រង្វាន់សម្រាប់ថ្ងៃខួបកំណើត៖ លោកអ្នកនឹងទទួលបានភេសជ្ជៈទំហំ Tall ចំនួន ១ ក្នុងខែនៃថ្ងៃកំណើតរបស់លោកអ្នកដូចបានរៀបរាប់ខាងក្រោម៖
  រង្វាន់ថ្ងៃខួបកំណើតនឹងត្រូវបានបញ្ចូលក្នុងគណនីរបស់លោកអ្នកដោយស្វ័យប្រវត្តិនៅថ្ងៃទី១នៃខែកំណើតរបស់លោកអ្នក ។ ការផ្តល់អោយនូវរង្វាន់ខួបកំណើតនេះនឹងផុតកំណត់នៅថ្ងៃបន្ទាប់នៃខែកំណើត ។ លោកអ្នកត្រូវបង្ហាញកាត Starbucks ដែលបានបានចុះបញ្ជីក្នុងប្រព័ន្ធរួច ឬបារកូដនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia ទៅកាន់បុគ្គលិក Starbucks នៅក្នុងហាង Starbucks ដើម្បីប្តូរយករង្វាន់របស់លោកអ្នក ។ លោកអ្នកទទួលបានរង្វាន់សម្រាប់ថ្ងៃកំណើតតែមួយប៉ុណ្ណោះ ដោយមិនគិតពីចំនួនកាត Starbucks ដែលបានចុះបញ្ជី ដែលអ្នកមានឡើយ ។ រង្វាន់សម្រាប់ថ្ងៃកំណើតអាចប្តូរបានតែនៅក្នុងហាង Starbucks នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ហើយមិនត្រូវបានអនុវត្តចំពោះភេសជ្ជៈដែលរៀបចំស្រេចនៅក្នុងដបនោះទេ (ready-to-drink bottled beverages) ។
- រង្វាន់ភេសជ្ជៈមិនគិតថ្លៃ៖ លោកអ្នកនឹងទទួលបានភេសជ្ជៈធ្វើដោយដៃ ទំហំ Tall ចំនួនមួយ (១) តាមការជ្រើសរើសរបស់លោកអ្នក សម្រាប់រាល់ផ្កាយចំនួន មួយរយ (១០០) ដែលលោកអ្នកទទួលបានបន្ថែមពីលើផ្កាយចំនួនពីររយ (២០០) ដែលលោកអ្នកត្រូវមាន ដើម្បីទទួលបានកម្រិតអត្ថប្រយោជន៍សមាជិកមាស ដូចបានរៀបរាប់ខាងក្រោម៖

រង្វាន់ភេសជ្ជៈមិនគិតថ្លៃរបស់លោកអ្នកនឹងត្រូវបានបញ្ចូលទៅក្នុងគណនីរបស់លោកអ្នកដោយស្វ័យប្រវត្តិក្នុងរយៈពេលប្រមាណសែសិបប្រាំបី (៤៨) ម៉ោងបន្ទាប់ពីលោកអ្នកទទួលបានផ្កាយចំនួន មួយរយ (១០០)

បន្ថែម ។ រង្វាន់ភេសជ្ជៈមិនគិតថ្លៃនេះនឹងត្រូវផុតកំណត់បន្ទាប់ពីរយៈពេលចំនួន មួយ (១) ខែ គិតចាប់ពីថ្ងៃដែលរង្វាន់ភេសជ្ជៈមិនគិតថ្លៃនោះ ត្រូវបានបញ្ចូលទៅក្នុងគណនីរបស់លោកអ្នក ។ លោកអ្នកត្រូវតែយកកាត Starbucks របស់លោកអ្នក ឬបារកូដក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia មកបង្ហាញបុគ្គលិកក្នុងហាង Starbucks ដើម្បីប្តូរយករង្វាន់របស់លោកអ្នក និងទទួលបានរង្វាន់ភេសជ្ជៈមិនគិតថ្លៃ ។ លោកអ្នកនឹងទទួលបានរង្វាន់ភេសជ្ជៈមិនគិតថ្លៃចំនួនមួយ (១) នៅពេលណាដែលលោកអ្នកមានផ្កាយចំនួន មួយរយ (១០០) បន្ថែមទៀត ។ រង្វាន់ភេសជ្ជៈមិនគិតថ្លៃ អាចប្តូរយកបានតែនៅក្នុងហាង Starbucks នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ហើយមិនត្រូវបានអនុវត្តចំពោះភេសជ្ជៈដែលរៀបចំស្រេចនៅក្នុងដបនោះទេ (ready-to-drink bottled beverages) ។

- លោកអ្នកនឹងទទួលបានផ្កាយបន្ថែមចំនួនប្រាំ (៥) សម្រាប់រាល់ការជាវភេសជ្ជៈ ផ្តល់ជូនមានកំណត់នីមួយៗ (promotional beverage) ក្នុងសប្តាហ៍ដំបូងនៃការចេញលក់ ។
- លោកអ្នកនឹងទទួលបានផ្កាយបន្ថែមចំនួនប្រាំពីរ (៧) សម្រាប់រាល់ការជាវផលិតផលប្រើប្រាស់ (serve-ware) ។
- ការផ្តល់ជូនពិសេស និង/ឬ លិខិតអញ្ជើញ៖ លោកអ្នកអាចទទួលបាននូវការផ្តល់ជូនពិសេស និង/ឬ លិខិតអញ្ជើញដើម្បីចូលរួមក្នុងព្រឹត្តិការណ៍នានា ដែលបានរៀបចំឡើងដោយ ឬសម្រាប់ Starbucks តាមរយៈ អ៊ីម៉ែល ឬលិខិតអញ្ជើញ តាមឆន្ទានុសិទ្ធិរបស់ Starbucks ។ លោកអ្នកត្រូវផ្តល់ការព្រមព្រៀងចូលរួមដើម្បីទទួលបានការផ្តល់ជូនសម្រាប់កម្មវិធីពិសេសពី Starbucks ហើយតម្រូវអោយលោកអ្នកផ្តល់អ៊ីម៉ែល លេខទូរស័ព្ទ និងអាសយដ្ឋាន ដើម្បីទទួលបានការផ្តល់ជូនពិសេស និង/ឬ លិខិតអញ្ជើញរបស់លោកអ្នក ។ ការផ្តល់ជូនពិសេស និង/ឬ លិខិតអញ្ជើញ អាចកំណត់បានផ្សេងៗគ្នា ដោយអាស្រ័យលើចរិតលក្ខណៈ និងជម្រើសនៃការជាវ ។ ការផ្តល់ជូនពិសេស អាចរួមមានការបញ្ចុះតម្លៃលើអាហារ ភេសជ្ជៈ និងទំនិញដោយមានចិរៈវេលាកំណត់ ។ ការផ្តល់ជូនពិសេស អាចមានការកំហិតជាក់លាក់ណាមួយ រួមមានកាលបរិច្ឆេទផុតកំណត់ និងការផ្តល់រយៈកំណត់សម្រាប់ការប្តូរយករង្វាន់ ។ រាល់ការផ្តល់ជូនពិសេស ត្រូវធ្វើឡើងដោយបុគ្គលលោកអ្នកផ្ទាល់ប៉ុណ្ណោះ ហើយមិនអាចចែករំលែក ថតចម្លង ឬផ្ទេរបានទេ ។ លោកអ្នកអាចនឹងត្រូវបានទាមទារឱ្យបង្ហាញកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធរបស់លោកអ្នក ឬបារកូដក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia មកជាមួយដើម្បីទទួលបានការផ្តល់ជូនពិសេសនេះ ។ សូមអានព័ត៌មានលម្អិតពាក់ព័ន្ធនឹងការផ្តល់ជូនទាំងនេះឱ្យបានប្រុងប្រយ័ត្នដើម្បីទទួលបានព័ត៌មានជាក់លាក់ កាលបរិច្ឆេទផុតកំណត់ ការកម្រិត និងការដាក់កំហិតផ្សេងៗ នៅពេលការផ្តល់ជូននោះ បានបញ្ចូលក្នុងគណនីរបស់អ្នក ។

  លោកអ្នកត្រូវទទួលខុសត្រូវចំពោះការធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងគណនី Starbucks Rewards របស់លោកអ្នក និងត្រូវធានាថាព័ត៌មានដែលលោកអ្នកបានបញ្ចូលទៅក្នុងគណនីរបស់លោកអ្នក ជាព័ត៌មានដែលត្រឹមត្រូវ និងជាព័ត៌មានចុងក្រោយគ្រប់ពេលវេលា រួមទាំងអ៊ីម៉ែល និងអាសយដ្ឋានរបស់លោកអ្នកក្នុងគេហទំព័រ Starbucks ។ ប្រសិនបើព័ត៌មានដែលលោកអ្នកបានផ្តល់អោយ ជាព័ត៌មានដែលមិនត្រឹមត្រូវ ឬមិនមែនជាព័ត៌មានចុងក្រោយ លោកអ្នកនឹងមិនអាចទទួលបានការផ្តល់ជូនពិសេស ឬលិខិត

អញ្ជើញទេ ។ លោកអ្នកអាចមើល ឬតាមដានការផ្តល់ជូនពិសេស និង/ឬលិខិតអញ្ជើញរបស់លោកអ្នក ដែលមានក្នុងគេហទំព័រ Starbucks ឬនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia ។

៩. លក្ខខណ្ឌផ្សេងៗ

៩.១ មិនមានការគិតកម្រៃសេវាសម្រាប់ការចុះឈ្មោះចូលជាសមាជិកកម្មវិធី Starbucks Rewards នោះទេ ប៉ុន្តែ ដើម្បីធ្វើការចុះឈ្មោះចូលទៅក្នុងគណនី Starbucks Rewards លោកអ្នកត្រូវមានកាត Starbucks ដែលមានទឹកប្រាក់យ៉ាងតិចបំផុត ចំនួន ប្រាំ (៥) ដុល្លារអាមេរិក ។ ផ្កាយដែលបានសន្សំទុកតាមរយៈកម្មវិធី Starbucks Rewards មិនមានតម្លៃជាសាច់ប្រាក់នោះទេ ។

៩.២ Starbucks អាចធ្វើការណែនាំលើកម្មវិធីពិសេសដែលទាក់ទងនឹងកម្មវិធី Starbucks Rewards ដែលលក្ខខណ្ឌនៃការប្រើប្រាស់នេះ អាចនឹងត្រូវបានផ្លាស់ប្តូរអាស្រ័យតាមកម្មវិធីដែលបានណែនាំនោះ ។

៩.៣ ប្រសិនបើកាត Starbucks របស់លោកអ្នកត្រូវបានបាត់ ខូចខាត ឬត្រូវបានគេលួច លោកអ្នកអាចនឹងបាត់បង់សមតុល្យដែលមាននៅក្នុងកាត Starbucks របស់លោកអ្នក ប៉ុន្តែចំនួនផ្កាយដែលមាននៅក្នុងកាតនោះនឹងមិនត្រូវបាត់បង់ឡើយ ក្នុងករណីដែលកាត Starbucks របស់លោកអ្នកបានចុះបញ្ជីរួចហើយនៅក្នុងប្រព័ន្ធ ។ ប្រសិនបើលោកអ្នកជាសមាជិករបស់កម្មវិធី Starbucks Rewards លោកអ្នកអាចការពារចំនួនផ្កាយ និងសមតុល្យដែលមាននៅក្នុងគណនី Starbucks Rewards របស់លោកអ្នកបានតាមរយៈការជូនដំណឹងមកកាន់យើងខ្ញុំតាមរយៈគេហទំព័រ http://www.starbucks.com.kh/card ឬនៅក្នុងកម្មវិធីទូរស័ព្ទ Starbucks Cambodia ឬក៏អាចទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលសេវាកម្មអតិថិជន Starbucks Rewards តាមរយៈលេខទូរស័ព្ទ (៨៥៥) ២៣ ៩៨៦ ៥៩១ ដោយបញ្ជាក់ពីការណែនាំរបស់លោកអ្នក ក្នុងករណីដែលកាតរបស់លោកអ្នកត្រូវបានបាត់បង់ ខូចខាត ឬត្រូវបានគេលួច ។ ប្រសិនបើលោកអ្នកមានកាត Starbucks តែមួយ លោកអ្នកអាចស្នើសុំធ្វើកាតថ្មីមកកាន់យើងខ្ញុំបាន ហើយសមតុល្យដែលមានក្នុងកាត Starbucks របស់លោកអ្នក ដែលបានបាត់បង់ ខូតខាត ឬដែលត្រូវបានគេលួច នឹងត្រូវផ្ទេរចូលទៅក្នុងកាតថ្មីនោះ ។ លោកអ្នកអាចបន្តប្តូរ យករង្វាន់ដែលមិនទាន់បានប្តូរ ក្នុងកំឡុងពេលមានសុពលភាព ដោយប្រើកាតថ្មីនេះបាន បើមិនដូច្នេះទេ សមតុល្យដែលមាននៅក្នុងកាត Starbucks ដែលបានបាត់បង់ ខូតខាត ឬត្រូវបានគេលួច អាចនឹងត្រូវបានផ្ទេរចូលទៅក្នុងកាត Starbucks ផ្សេងទៀតរបស់លោកអ្នក ។

៩.៤ ផ្កាយ រង្វាន់ កាត Starbucks និងគណនីរបស់លោកអ្នក ដែលបានចុះបញ្ជីក្នុងកម្មវិធី Starbucks Rewards គឺសម្រាប់ប្រើប្រាស់តែខ្លួនរបស់លោកអ្នកផ្ទាល់ ហើយនឹងមិនអាចទិញ លក់ ផ្ទេរ ឬផ្តល់ឱ្យ ឬចែករំលែកជាមួយក្រុមគ្រួសារ មិត្តភក្តិ ឬអ្នកដទៃ ឬប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្មណាមួយឡើយ ។ លោកអ្នកអាចមានគណនី Starbucks Rewards តែមួយ (១) គត់ដែលប្រើប្រាស់សម្រាប់ខ្លួនរបស់លោកអ្នកផ្ទាល់ ។

៩.៥ Starbucks រក្សាសិទ្ធិលុបចោលគណនី Starbucks Rewards ដែលក្នុងនោះកាត Starbucks ដែលបានចុះបញ្ជីក្នុងប្រព័ន្ធទាំងអស់ នឹងត្រូវបានផុតកំណត់ ឬបិទដំណើរការតាមករណីជាក់ស្តែងនីមួយៗ ដោយពុំចាំបាច់មានការជូនដំណឹង នឹងតាមរយៈឆន្ទានុសិទ្ធិរបស់ Starbucks តែមួយគត់ ។ ក្នុងករណីដែលគណនី Starbucks Rewards របស់លោកអ្នកត្រូវបានលុបចោល ឬលែងមានសុពលភាព នោះរាល់ផ្កាយដែលបានសន្សំទុកក្នុងកាត Starbucks របស់លោកអ្នក នឹងត្រូវទុកជាមោឃៈ ។

៩.៦ Starbucks រក្សាសិទ្ធិក្នុងការផ្អាកដំណើរការកាត Starbucks ដែលបានចុះបញ្ជី និង/ឬ បិទគណនី Starbucks Rewards និង/ឬ បញ្ឈប់ការចូលរួមរបស់លោកអ្នកក្នុងកម្មវិធី Starbucks Rewards ដោយពុំចាំបាច់មានការជូនដំណឹង និងតាមរយៈឆន្ទានុសិទ្ធិរបស់Starbucks តែមួយគត់ ក្នុងករណីដែល Starbucks យល់ឃើញថាលោកអ្នកបានរំលោភបំពានលើលក្ខខណ្ឌនៃការប្រើប្រាស់ទាំងនេះ ឬ អ្នកមានគណនី Starbucks Rewards លើសពីមួយ (១) ឬការប្រើគណនី Starbucks Rewards របស់លោកអ្នក មិនទទួលបានការអនុញ្ញាត ហើយជាប្រើប្រាស់ដោយមានការបោកបញ្ឆោត ក្លែងបន្លំ ឬ មិនស្របច្បាប់ ។ តាមរយៈឆន្ទានុសិទ្ធិរបស់ Starbucks Starbucks អាចផ្អាក លុបចោល ឬបញ្ចូលគណនីណាដែលដូចគ្នា ។ ក្នុងករណីដែលការចូលរួមរបស់លោកអ្នកនៅក្នុងកម្មវិធី Starbucks Rewards ត្រូវបានបញ្ឈប់ នោះផ្កាយដែលបានសន្សំទុកនៅក្នុងគណនីរបស់លោកអ្នកទាំងអស់ នឹងត្រូវចាត់ទុកជាមោឃៈ ។

១០. ការលុបចោលនូវគណនី Starbucks Rewards

លោកអ្នកអាចធ្វើការស្នើសុំលុបចោលនូវគណនី Starbucks Rewards របស់លោកអ្នកនៅពេលណាក៏បានតាមរយៈ ដំណើរការលុបចោលគណនី ដែលបានផ្តល់ឲ្យនៅក្នុងគេហទំព័រ Starbucks ឬ កម្មវិធីទូរសព្ទ Starbucks Cambodia ។ សូមធ្វើការកត់ចំណាំថា (ក) រាល់សំណើលុបចោលគណនីទាំងអស់ត្រូវបានសន្មតថាស្ថាពរ និងមិនអាចធ្វើការត្រឡប់ក្រោយបានទេ ប្រសិនបើសំណើត្រូវបានអនុម័ត និង (ខ) ក្រោយពេលដែលគណនីត្រូវបានលុបចោល រាល់ព័ត៌មាន និងអត្ថប្រយោជន៍ទាំងឡាយដែលភ្ជាប់នឹងគណនីដែលត្រូវបានលុបចោល នឹងមិនអាចធ្វើការប្រើប្រាស់ ឬ ស្រោចស្រង់មកវិញបានទេ រួមបញ្ចូលទាំងប្រវត្តិនៃការប្រើប្រាស់គណនី សមតុល្យកាត Starbucks ចំនួនផ្កាយ ព្រមទាំងរង្វាន់ផ្សេងៗទៀត ។

១១. ការប្តឹងទាមទារ និងវិវាទ

១១.១ រាល់ការប្តឹងទាមទារ និងវិវាទដែលកើតចេញពី ឬដែលទាក់ទងនឹងលក្ខខណ្ឌនៃការប្រើប្រាស់ ឬកម្មវិធី Starbucks Rewards នឹងត្រូវបញ្ជូនទៅ និងដោះស្រាយដោយមជ្ឈមណ្ឌលជាតិមជ្ឈការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា ស្របតាមវិធានរបស់មជ្ឈមណ្ឌលដែលមានសុពលភាពអនុវត្តនៅពេលចាប់ដំណើរមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធាននោះត្រូវចាត់ទុកថាបានបញ្ចូលជាផ្នែកមួយនៃប្រការនេះ ។ ទីកន្លែងធ្វើមជ្ឈត្តការនឹងត្រូវធ្វើឡើងក្នុងរាជធានីភ្នំពេញ ។ ដំណើរការមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួនមួយ (១) រូប ។ ហើយភាសាដែលត្រូវប្រើប្រាស់ក្នុងដំណើរការនេះជាភាសាអង់គ្លេស ។

១១.២ រាល់មជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការត្រូវមានអានុភាពចាប់បង្ខំ ចាប់ពីកាលបរិច្ឆេទដែលបានធ្វើឡើង ហើយភាគីយល់ព្រមបោះបង់ចោលសិទ្ធិទាំងឡាយក្នុងការបញ្ជូនបញ្ហាច្បាប់ និងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ទៅលើអង្គច្បាប់ និង/ឬ អង្គសេចក្តីទៅកាន់តុលាការណាមួយ ។ ការសំរេចសេចក្តីលើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តការ អាចត្រូវបាន បញ្ជូនទៅតុលាការណាមួយដែលមានយុត្តាធិការ ។

## ទំនាក់ទំនង

ប្រសិនបើលោកអ្នកមានសំនួរដែលពាក់ព័ន្ធនឹងកម្មវិធី Starbucks Rewards សូមមេត្តាទាក់ទងមកកាន់៖

Coffee Concepts (Cambodia) Limited.

អគារម៉ហ្គេនលេខ៣៨៨ សាលលេខ៧-១១ ជាន់ទី១២ ផ្លូវសុភមង្គល

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

មជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់កម្មវិធី Starbucks Rewards៖ (៨៥៥) ២៣ ៩៨៦ ៥៩១